ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តតាកែវ

សំណុំរឿងព្រហ្មទណ្ឌលេខ: ២៤១
ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣
ជំនុំជម្រះ
លេខ: ៤៣២
ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣
សាលក្រម
លេខ: ៣០ "ក"
ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាដំបូងខេត្តតាកែវ នាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤ ដោយមានសមាសភាពដូចតទៅ:

## សមាសភាពជំនុំជម្រះ

លោកជំទាវ [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោកស្រី [redacted] ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តតាកែវ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ: ២៤១ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ដែលមានទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងសំណង់ មានទីកន្លែងកំណើតភូមិពីរ ឃុំមិត្តភាព ស្រុកមិត្តភាព ខេត្តព្រះសីហនុ និងទីលំនៅបច្ចុប្បន្ននៅពន្ធនាគារខេត្តតាកែវ ឪពុកឈ្មោះ [redacted] សារឹម (ស្លាប់) ម្តាយឈ្មោះ [redacted] គឹមលី (រស់) ប្រពន្ធឈ្មោះ [redacted] ផាន់ណា (រស់) មានកូនចំនួន០១នាក់ ជានីតិជន ។

ជាប់ពិរុទ្ធពីបទ: អំពើលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិកន្សោមក្លែង ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងបទ: អំពើលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិត្រពាំងអង្គ ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យទណ្ឌិតឈ្មោះ [redacted] ភក្តី ។



Scanned with CamScanner

**-បានឃើញ:** ពាក្យស្នើសុំស្រួបទោស ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ទណ្ឌិត ឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៥៥ឆ្នាំ។

**-បានឃើញ:** សាលដីកាស្ថាពរលេខ: **៩៨ ក្រVI"ណ"/២៨-៨-១៨** ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ។

**-បានឃើញ:** សាលដីកាស្ថាពរលេខ: **១២៧ ក្រ II (ញ)** ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ។

**-បានឃើញ:** ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: ៣៧៧ ដ.ស.ស /២៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ ។

**-បានឃើញ:** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៤៣២ ដចត/២៣ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តតាកែវ ។

## អង្គហេតុ

ទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៥៥ឆ្នាំ ត្រូវបានសាលាឧទ្ធរណ៍ភ្នំពេញ ធ្វើការជំនុំជម្រះ និងបានផ្តន្ទាទោសតាមអំណាចសាលដីកាស្ថាពរចំនួនពីរ ទី១លេខ: **៩៨ ក្រVI"ណ"/២៨-៨-១៨** ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០៧ (ប្រាំពីរ) ឆ្នាំ** ពីបទ: **អំពើលួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិកន្ទ្រោមក្លែង ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងសាលដីកាស្ថាពរលេខ: **១២៧ ក្រ II (ញ)** ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០៥ (ប្រាំ) ឆ្នាំ** ពីបទ: **អំពើលួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិត្រពាំងអង្គ ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។ ដោយសាលដីកាទាំងពីរខាងលើនេះពុំមានភាគីណាមួយចូលមកប្តឹងសាទុក្ខទៅតុលាការជាន់ខ្ពស់នោះទេ និងបានចូលជាស្ថាពររួចរាល់អស់ហើយដែរ ។ មួយវិញទៀត ចំពោះបទល្មើសដែលតុលាការបានសម្រេចផ្តន្ទាទោសលើទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៥៥ឆ្នាំ ជាប្រភេទបទល្មើសត្រួតគ្នា ដោយទណ្ឌិតរូបនេះបានដាក់ពាក្យស្នើសុំស្រួបទោសលើសាលដីកាស្ថាពរទាំងពីរ ខាងលើនេះបញ្ចូលគ្នាចូលមកសាលាដំបូងខេត្តតាកែវ ។

## នាពេលសវនាការ

-ទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៥៥ឆ្នាំ បានឆ្លើយថា ចំពោះសាលដីកាទាំងពីរនេះ បានចូលជាស្ថាពររួចហើយ ខ្ញុំបាទមិនបានប្តឹងសាទុក្ខទៅតុលាការជាន់ខ្ពស់នោះទេដោយសាលដីកាស្ថាពរលេខ: ៩៨ ក្រVI"ណ"/២៨-៨-១៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេលចំនួន **០៧ (ប្រាំពីរ) ឆ្នាំ**



Scanned with CamScanner

និងសាលដីកាស្ថាពរលេខ: ១២៧ ក្រ II (ញ) ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០៥ (ប្រាំ) ឆ្នាំ ហើយខ្ញុំបាទបានអនុវត្តទោសក្នុងពន្ធនាគារបានចំនួន ៦ (ប្រាំមួយ) ឆ្នាំ និង ៩ (ប្រាំបួន) ខែ រួចហើយនៅពេលនេះ ខ្ញុំបាទបានកែប្រែខ្លួនបានល្អជាច្រើន និងមិនដែលបង្កទំនាស់ក្នុងពន្ធនាគារនោះទេ ហើយខ្ញុំបាទស្នើសុំឱ្យតុលាការស្រូបទោសចំពោះសាលដីកាទាំងពីរនេះផង ។

-សេចក្តីកត់សម្គាល់របស់ទណ្ឌិត: គ្មាន ។

-មេធាវីការពារសិទ្ធិឱ្យទណ្ឌិតឈ្មោះ [redacted] ភក្តី ធ្វើសេចក្តីសន្និដ្ឋានការពារថា: ឆ្លងតាមការសួរដេញដោលឃើញថា កូនក្តីរបស់ខ្ញុំបាទអនុវត្តទោសនៅក្នុងពន្ធនាគារកន្លងមក មានការភ្ញាក់រលឹកបានដឹងអំពីកំហុស និងមានការសោកស្តាយចំពោះអំពើដែលខ្លួនបានប្រព្រឹត្តកំហុសឆ្គងកន្លងមក និងមានឪពុកម្តាយដែលមានវ័យចាស់ជរាត្រូវទទួលបន្ទុករកស៊ីចិញ្ចឹមផងដែរ ហេតុដូច្នេះ ខ្ញុំបាទជាមេធាវីស្នើសុំឱ្យតុលាការ សម្រេចស្រូបទោសក្នុងសាលដីកាស្ថាពរលេខ: ១២៧ ក្រ II (ញ) ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ មួយផ្នែកចំនួន០៥ (ប្រាំ) ឆ្នាំ បញ្ចូលទៅក្នុងសាលដីកាស្ថាពរលេខ: ៩៨ ក្រVI"ណ"/២៨-៨-១៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដោយឱ្យទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៤៤ឆ្នាំ ដោយអនុវត្តទោសនៅក្នុងពន្ធនាគារត្រឹមរយៈពេលសរុបចំនួន ០៧ (ប្រាំពីរ) ឆ្នាំ បានហើយ ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការសួរដេញដោលឃើញថា ទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៤៤ឆ្នាំ បានឆ្លើយសារភាពថា ខ្លួនបានទទួលរងទោសតាមអំណាចសាលដីកាចំនួនពីរ ដែលបានចូលជាស្ថាពររួចហើយ ដែលសាលដីកាទីមួយ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ០៧ (ប្រាំពីរ) ឆ្នាំ និងសាលដីកាទីពីរ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ០៥ (ប្រាំ) ឆ្នាំ ខ្លួនបានអនុវត្តទោសបានចំនួន ៦ (ប្រាំមួយ) ឆ្នាំ និង ៩ (ប្រាំបួន) ខែ រួចហើយ ដោយបានកែប្រែខ្លួនបានយ៉ាងល្អនៅពន្ធនាគារ និងមិនដែលបង្កទំនាស់នៅក្នុងពន្ធនាគារនោះទេ ហេតុដូច្នេះ តំណាងអយ្យការស្នើសុំឱ្យតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

-សំណូមពរចុងក្រោយរបស់ទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៤៤ឆ្នាំ ខ្ញុំបាទសំណូមពរដល់តុលាការមេត្តាសម្រេចស្រូបទោសសាលដីកាទាំងពីរនេះឱ្យខ្ញុំបាទផង

-ក្រោយពីបានស្តាប់ចម្លើយរបស់ទណ្ឌិត

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង

-ក្រោយពីបានធ្វើសេចក្តីកត់សម្គាល់របស់ទណ្ឌិត

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពារសុំរបស់មេធាវីការពារឱ្យទណ្ឌិត

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ទណ្ឌិត

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សំអាងហេតុ

១-ពាក្យស្នើសុំស្រូបទោសចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៤៤ឆ្នាំ ឃើញថា មានលក្ខណៈត្រឹមត្រូវតាមបញ្ញត្តិមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ហេតុនេះតុលាការអាចទទួលយកពាក្យស្នើសុំស្រូបទោសខាងលើនេះមកចំណាត់ការតាមនីតិវិធីច្បាប់បាន ។

២-សាលដីកាស្ថាពរលេខៈ ៩៨ ក្រVI"ណ"/២៨-៨-១៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ បានសម្រេចដាក់ពន្ធនាគារលើទណ្ឌិតកំណត់រយៈពេលចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ពីបទៈ **អំពើលួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិកន្សោមក្លែង ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣-សាលដីកាស្ថាពរលេខៈ ១២៧ ក្រ II (ញ) ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ បានសម្រេចដាក់ពន្ធនាគារលើទណ្ឌិតកំណត់រយៈពេលចំនួន ០៥ (ប្រាំ) ឆ្នាំ ពីបទៈ **អំពើលួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិត្រពាំងអង្គ ឃុំព្រៃស្លឹក ស្រុកទ្រាំង ខេត្តតាកែវ កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤-សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យទណ្ឌិតឈ្មោះ [redacted] ភក្តី គប្បីតុលាការពិចារណាសម្រេចទៅតាមអង្គហេតុ និងអង្គច្បាប់ ។

៥-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការថា តំណាងអយ្យការស្នើសុំឱ្យតុលាការពិចារណា និងសម្រេចតាមច្បាប់ ។ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

៦-ចំពោះទោសដាក់ពន្ធនាគារដែល តុលាការបានសម្រេចផ្តន្ទាទោសលើទណ្ឌិតឈ្មោះ [redacted] ភក្តី ទាំងពីរសាលដីកានេះ គឺមានទោសសរុបចំនួន ១២ (ដប់ពីរ) ឆ្នាំ ហើយចំពោះទណ្ឌកម្មដាក់ពន្ធនាគារដែលច្បាប់បានកំណត់ក្នុងបទៈ **អំពើលួចមានស្ថានទម្ងន់ទោស** នេះគឺមានចន្លោះពី ០៣ (បី) ឆ្នាំ ទៅ ១០ (ប្រាំ) ឆ្នាំ ដែលមិនអាចឱ្យតុលាការធ្វើការសម្រេចប្រកាសទោសក្នុងព្រំដែនអតិបរមា នៃទោសដែលខ្ពស់ជាងគេបានទេ ទោះបីជាការអនុវត្តទោសនៅក្នុងពន្ធនាគារកន្លងមកទណ្ឌិតឈ្មោះ [redacted] ភក្តី មានការភ្ញាក់រលឹកបានដឹងអំពីកំហុស និងមានការសោកស្តាយចំពោះអំពើដែលខ្លួនបានប្រព្រឹត្តកំហុសឆ្គងកន្លងមកក៏ដោយ ព្រោះថាបទល្មើសដែលទណ្ឌិតបានប្រព្រឹត្តជាបទល្មើសឧក្រិដ្ឋ ដែលបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់សង្គម ។ ហេតុដូច្នេះតុលាការមិនអាចសម្រេចស្រូបទោសក្នុងសាលដីកាស្ថាពរលេខៈ ១២៧ ក្រ II (ញ) ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ មួយផ្នែកចំនួន ០៥ (ប្រាំ) ឆ្នាំ បញ្ចូលទៅក្នុងសាលដីកាស្ថាពរលេខៈ

៩៨ ក្រVI"ណ"/២៨-៨-១៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ឱ្យទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៤៤ឆ្នាំ បានឡើយ ។

**ហេតុដូច្នេះសម្រេច**

១-លើកចោលពាក្យស្នើសុំស្រូបទោសចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៤៤ឆ្នាំ ជាអសារបង់ ។

២-ឱ្យទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៤៤ឆ្នាំ បន្តអនុវត្តទោសតាមអំណាចសាលដីកាស្ថាពរលេខ: ១២៧ ក្រ II (ញ) ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ និងសាលដីកាស្ថាពរលេខ: ៩៨ ក្រVI"ណ"/២៨-៨-១៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ។

-សាលក្រមនេះជំនុំជម្រះ ជាសាធារណៈ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤ ចំពោះមុខទណ្ឌិតឈ្មោះ [redacted] ភក្តី ភេទប្រុស អាយុ៤៤ឆ្នាំ ។

-ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១៥ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

តាកែវ, ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ2024

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner